ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កំពង់ធំ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤
នៅរដ្ឋបាល [illegible]
ក្រឡាបញ្ជី

[redacted]

**សាលាដំបូងខេត្តកំពង់ធំ**
-សំណុំរឿងព្រហ្មទណ្ឌលេខ: **២៥៦**
ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ: **៣៣៩**
ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣
-សាលក្រមព្រហ្មទណ្ឌលេខ: **៤៩(ខ)**
ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ធំ

-កាលបរិច្ឆេទបើកសវនាការជំនុំជម្រះ នៅថ្ងៃទី**២៧** ខែ**កញ្ញា** ឆ្នាំ**២០២៣** និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី**២៦** ខែ**តុលា** ឆ្នាំ**២០២៣** ។

**ដោយសមាសភាពចូលរួម ៖**

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ
-លោកស្រី [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជី**

-លោកស្រី [redacted] ក្រឡាបញ្ជីសវនាការ

**មេធាវី**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: **២៥៦** ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមាន៖

**<u>ជនជាប់ចោទ៖</u>**

១.ឈ្មោះ [redacted]**ឆេងអ៊ែន** ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted] ខេត្តកំពង់ធំ មុខរបរសិស្ស(រៀនភាសាកូរ៉េ) ឪពុកឈ្មោះ [redacted]**អ៊ុត** "រស់" ម្តាយឈ្មោះ [redacted]**សុផល់** "រស់" នៅលីវ កម្រិតវប្បធម៌៖ថ្នាក់ទី១២ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "**គ្មាន**"។ (ក្នុងឃុំ)

ត្រូវជាប់ចោទពីបទ៖ "**លួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ និងចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងចំណុចមុខផ្ទះជាងគំនូរឆ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

២.ឈ្មោះ [redacted] **ឃាន់** ភេទប្រុស កើតឆ្នាំ២០០៤ ជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] យួន "រស់" ម្តាយឈ្មោះ [redacted] កៀម "រស់" នៅលើវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "គ្មាន"។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ៖ "**សមគំនិតលួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៩, មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គីមស្រ៊ុន** ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ រស់នៅភូមិទី០៧ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ នៅចំណុចភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ, កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ នៅចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ និងកាលពី១១ ខែមេសា ឆ្នាំ២០២៣ នៅចំណុចមុខផ្ទះជាងគំនូរឆ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានករណី លួចដោយមានស្ថានទម្ងន់ទោស(ឆក់កាបូប)មួយបានកើតឡើងបង្កឡើងដោយឈ្មោះ [redacted] ឆេងអ័ន និងបក្ខពួក បានធ្វើសកម្មភាពជិះម៉ូតូ០១គ្រឿង ឆក់កាបូបជនរងគ្រោះបានសម្រេច។ ក្រោយកើតហេតុជនរងគ្រោះបានដាក់ពាក្យបណ្តឹងមកសមត្ថកិច្ចឱ្យជួយអន្តរាគមន៍។ ក្រោយមកសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] ឆេងអ័ន ដើម្បីកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធីច្បាប់។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: **២៨៣/២០២៣** ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

**-បានឃើញ** ដីកាដំណោះស្រាយបញ្ជូនទៅជំនុំជម្រះលេខ: **២៩១៥/២០២៣** ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

**-បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ: **៤៣៧៩ស.ព្រ** ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ឆេងអ័ន** — **វត្តមាន**

-ជនជាប់ចោទឈ្មោះ [redacted] **ឃាន់** — **អវត្តមាន**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គីមស្រ៊ុន** — **វត្តមាន**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ដូអ៊ាន** — **អវត្តមាន**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចន្ថា** — **អវត្តមាន**

-សាក្សីឈ្មោះ [redacted] **ឈុនឡេង** — **អវត្តមាន**

-មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] **សារិទ្ធ** — **អវត្តមាន**

-មេធាវីឈ្មោះ [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ — **វត្តមាន**

-មេធាវីឈ្មោះ [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ — **វត្តមាន**

[redacted]

## ដំណើរការសួរដេញដោលក្នុងពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ឆេងអ័ន** បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ម៉ោង០៣រសៀល រូបខ្លួនបានជិះម៉ូតូម៉ាកហុងដា ពណ៌ខ្មៅ ស៊េរី២០២០ ពាក់ផ្លាកលេខកំពង់ធំ1N-8207 តែម្នាក់ឯង និងបានឆក់កាបូបដៃអ៊ុំស្រីម្នាក់ដែលគាត់ដាក់ក្នុងកន្ត្រក់ម៉ូតូ នៅផ្លូវសណ្ឋាគារ កំពង់ធំ (ផាលេស) ស្ថិតនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ មុខផ្ទះជាងគំនូរភ្លាមសមុទ្រ រួចបានយកទៅមើលនៅចំណុចផ្លូវវៀងក្រុងស្ទឹងសែន ឃើញមានលុយ ១០០$ មួយសន្លឹក, លុយ ១៥០.០០០ រៀល និងទូរស័ព្ទម៉ាក OPPO F11 ចំនួន០១គ្រឿង និងឯកសារធនាគារមួយចំនួនទៀត ហើយខ្លួនបានជិះគេចទៅផ្ទះនៅស្រុកសន្ទុក ដោយទូរស័ព្ទបាន យកទៅលក់នៅតាំងក្រសាំងមិនចាំឈ្មោះយីហោ បានតម្លៃ ១២០.០០០ រៀល។ កន្លងមករូបខ្លួនធ្លាប់ឆក់កាបូបបានសម្រេចចំនួនពីរលើក ដោយ**លើកទី១** នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ម៉ោង១២:៣០នាទី តាមផ្លូវព្រៃគុយរូបខ្លួនបានជិះម៉ូតូម្នាក់ឯង បានឃើញស្រីចំណាស់ពីរនាក់ ជិះម៉ូតូមកបញ្ជោស់ពីខ្លួនដាក់កាបូបឃ្នូរនឹងដៃម៉ូតូខាងឆ្វេង ហើយបានជិះបកតាមពី ក្រោយពួកគាត់ វ៉ាម៉ូតូគាត់ ហើយលួកដៃយកកាបូបនោះ ឆែកឃើញលុយ ៨០.០០០ រៀល និងទូរស័ព្ទពីរគ្រឿង (ម៉ាកOPPO ពណ៌ខ្មៅ និងម៉ាកសាំស៊ុង ពណ៌មាស) លក់បានលុយចំនួន ២៦០.០០០ រៀល និង**លើកទី២** នៅថ្ងៃទី០៣ ខែមេសាឆ្នាំ២០២៣ រូបខ្លួន និងមិត្តភ័ក្តឈ្មោះ ខាន ឃាន់ ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះភ័ក្ត្រ ភេទប្រុស អាយុ២៣ឆ្នាំ រៀនភាសាកូរ៉េជាមួយគ្នា និងនាំគ្នាអង្គុយលេងនៅស្ទួនដំរីជាន់ខ្លា។ ពេលនោះរូបខ្លួនបានជិះម៉ូតូរបស់ខ្លួនចេញពីពួកគេ ដោយខ្លួនឯង តាមបណ្តោយផ្លូវជាតិលេខ៦ ស្ថិតនៅភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ចំណែកឈ្មោះ ខាន ឃាន់ ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះភ័ក្ត្រ ភេទប្រុស អាយុ២៣ឆ្នាំ ជិះតាមពីក្រោយជាមួយនឹងរូបខ្លួនទេ។ ហើយរូបខ្លួនបានឃើញស្ត្រីម្នាក់ជិះម៉ូតូមិនចាំម៉ាកតែឯង ស្របទិសគ្នា ហើយរូបខ្លួនបានធ្វើសកម្មភាពនៅខាងឆ្វេងដៃដោយលូកឆក់កាបូបនោះមិនបានសម្រេចម៉ូតូរបស់ជនរងគ្រោះដួល ហើយខ្លួនបានជិះគេចខ្លួន។ ចំណែកមិត្តភ័ក្តឈ្មោះ ខាន ឃាន់ ភេទប្រុស អាយុ១៩ឆ្នាំ រស់នៅក្នុង ភូមិជាមួយខ្លួន និងឈ្មោះភ័ក្ត្រ ភេទប្រុស អាយុ២៣ឆ្នាំ ទើបតែស្គាល់ទេ មិនដឹងពួកគេជិះម៉ូតូទៅណាទេ ដោយពួកគេមិនបានចូលរួមឆក់ជាមួយខ្លួនឡើយ។ ចំណែកនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ នៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ត្រូវសមត្ថកិច្ចចាប់ឃាត់រូបខ្លួន និងបានដកហូតទូរស័ព្ទម៉ាកOPPO ពណ៌ខ្មៅចំនួន០១គ្រឿង និងម៉ូតូម៉ាកហុងដា ពណ៌ខ្មៅ ស៊េរី២០២០ ពាក់ផ្លាកលេខកំពង់ធំ 1N-8207 ចំនួន០១គ្រឿង។

-ជនជាប់ចោទឈ្មោះ [redacted] **ឃាន់** បានឆ្លើយនាពេលសវនាការថា៖ ខ្លួនសូមធ្វើការសារភាពថាខ្លួនមិនដែលបានធ្វើសកម្មភាពលួច ឬសមគំនិតលួចអ្វីឡើយ។ ខ្លួនស្គាល់ឈ្មោះ [redacted] ឆេងអ័ន ដោយសារត្រូវជាបងប្អូនសាច់ឆ្ងាយ និងដោយសារមានអាយុប្រហាក់ប្រហែលគ្នាផង និងរៀនជាមួយគ្នាផង ក៏បានរាប់អានគ្នា។ ខ្លួនបានមកសិក្សានៅសាលាកូរ៉េ ជាមួយឈ្មោះ [redacted] ឆេងអ័ន ដែរ ដោយមានគោលបំណងប្រលងចេញទៅធ្វើការនៅប្រទេស កូរ៉េ។ ខ្លួនមិនដឹងថាឈ្មោះ [redacted] ឆេងអ័ន ធ្លាប់ធ្វើសកម្មភាពលួចនោះទេ ហើយឈ្មោះនេះក៏មិនដែលបបួលខ្លួនទៅធ្វើសកម្មភាពលួចរបស់អ្នកណាដែរ គឺខ្លួនបានដើរជាមួយតែនៅក្នុងសាលារៀនភាសាកូរ៉េ។ ថ្ងៃកើតហេតុ ខ្លួនបានទៅអង្គុយលេងនៅស្ទួនដំរីជាន់ខ្លាជាមួយឈ្មោះ ភ័ក្ត្រ និងឈ្មោះ [redacted] ឆេងអ័ន នេះ ហើយឈ្មោះ [redacted] អ័ន បាននិយាយថាទៅឆក់គេ តែខ្លួនមិនចាប់អារម្មណ៍ ហើយមួយសន្ទុះក្រោយមកក៏បាត់ឈ្មោះ [redacted] អ័ន មិនដឹងទៅណា ខ្លួនក៏ត្រឡប់ទៅផ្ទះដែរ។ ខ្លួនពិតជាមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **អ៊ុត គឹមស្រ៊ុន** បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ម៉ោង ១៦:៣០នាទី រូបខ្លួនបានធ្វើដំណើរចេញពីធនាគារអេស៊ីលីដា គោលបំណងទៅផ្ទះ។ លុះមកដល់ចំណុចផ្លូវមាត់ហាវទី១ ស្ថិតនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ បានឃើញមនុស្សប្រុសម្នាក់ជិះម៉ូតូម៉ាកហុងដា ពណ៌ខ្មៅ កាបន្ទះពណ៌ស ពាក់មួកសុវត្ថិភាព បាន ឆក់កាបូបខ្លួនដែលព្យួរនៅខាងឆ្វេងដៃរួចក៏ជិះម៉ូតូយ៉ាងលឿនទៅទិសខាងលិច។ នៅក្នុងកាបូបខ្លួនមាន ទូរស័ព្ទម៉ាកអូប៉ូ ពណ៌ស, ប្រាក់ខ្មែរចំនួន ២០.០០០ រៀល, ប្រាក់ដុល្លារអាមេរិកចំនួន ១០០$ និងឯកសារសំខាន់ៗផ្ទាល់ខ្លួនមួយចំនួនទៀត។ ក្រោយមកសមត្ថកិច្ចបានធ្វើការចាប់ឃាត់ខ្លួនឈ្មោះ ឆន ឆេងអ័ន ភេទប្រុស ហើយសមត្ថកិច្ចបានប្រគល់ទូរស័ព្ទមកឱ្យរូបខ្លួនវិញ។ ហើយខ្លួនសូមដកពាក្យបណ្តឹងឈប់ប្តឹងលើជននេះទៀតហើយដោយសារខ្លួនបានទទួលសំណងបញ្ចប់រឿង

កំពង់ធំ ថ្ងៃទី.២៥...ខែ....ឆ្នាំ.២០២៤

[redacted]

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឌុអ៊ាន បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ម៉ោង១២:៣០នាទី រូបខ្លួនជិះម៉ូតូម៉ាកវេវពីព្រៃគុយ ត្រឡប់មកផ្ទះនៅភូមិកំពង់ក្របៅ ជិះមកដល់ព្រំប្រទល់ព្រៃគុយ ស្រាប់តែមានក្មេងប្រុសម្នាក់មិនស្គាល់ឈ្មោះ ជិះម៉ូតូម៉ាកឌ្រីម ពណ៌ខ្មៅ កាំបន្ទះពណ៌ស អាវក្រៅដៃវែង ពណ៌ក្រម៉ៅ ពាក់មួកសុវត្ថិភាព ពណ៌ស បានមកទន្ទឹមខ្លួនឆក់កាបូប ពណ៌ក្រឡាការ៉ូពីដៃម៉ូតូរបស់ខ្លួន រួចគេចទៅលិចបាត់ បណ្តាលឲ្យខ្លួនដួលម៉ូតូតែគ្មានរបួស។ ក្នុងកាបូបមានទូរស័ព្ទ០២គ្រឿង(ម៉ាកអូ ប៉ូ ពណ៌ ស និងម៉ាកសាំស៊ុង ពណ៌ដី និងប្រាក់ ៨០.០០០ រៀល) ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ខ្លួន និងក្មួយស្រី បានជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ស៊េរី២០១២ ចេញពីផ្សារកំពង់ធំ សំដៅទៅផ្ទះនៅភូមិពោធិ៍សែនស្នាយ មកដល់ចំណុចម្តុំស្ពានធំ ឃើញមនុស្សពីរនាក់មិនស្គាល់ មិនចាំភិនភាគ ជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម កាំបន្ទះ ពណ៌ខ្មៅក្នុងទិសដៅស្របគ្នាតែ ពួកវាជិះពីក្រោយខ្លួន នៅពេលពួកវាមកដល់ ទន្ទឹមខ្លួនខាងឆ្វេងដៃ អ្នកជិះពីក្រោយលូកយកកាបូបខ្លួនស្ពាយនោះ ខ្លួនបានដណ្តើមកាបូបខ្លួនពីរដងក៏ដាច់ខ្សែកាបូបធ្លាក់ ទៅលើថ្នល់ ហើយខ្លួនបានធ្លាក់ពីលើម៉ូតូបណ្តាលឲ្យរបួសចង្កេះ, កំភួនជើងឆ្វេង, កំភួនដៃឆ្វេង, កែងដៃឆ្វេង និងម្រាមជើងឆ្វេង។ ចំណែកជនល្មើសបានជិះហួសសំដៅរង្វង់មូលតាក្រហមក ខ្លួនមិនប្តឹងទាមទារសំណងអ្វីនោះទេ និងសុំដកពាក្យបណ្តឹងផងដែរ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំដូចតទៅ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ, តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទ, តាមការស្តាប់ចម្លើយ និងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់ ព្រមទាំងការពិនិត្យភស្តុតាងពាក់ព័ន្ធដែលមាននៅក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថា៖ ឈ្មោះ [redacted]ឆេងអ័ន ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ "**លួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ, កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងចំណុចមុខផ្ទះជាងគំនូរផ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។ ចំណែកឯឈ្មោះ [redacted] **ឃាន់** ភេទប្រុស កើតឆ្នាំ២០០៤ ជាតិខ្មែរ ពិតជាមិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ថាជននេះ បានប្រព្រឹត្តអំពើ "**សមគំនិតលួចមានស្ថានទម្ងន់ទោស(ឆក់កាបូប លុយ)**" ប្រព្រឹត្តនៅភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**២៩**, មាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះតំណាងអយ្យការប្តឹងសុំឱ្យជននេះរួចខ្លួនពីបទចោទ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ឆេងអ័ន** បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូមគោរពអង្គសវនាការទាំងមូល ខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឆេងអ័ន សូមធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅ: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងការពិនិត្យភស្តុតាងពាក់ព័ន្ធដែលមាននៅក្នុងសំណុំរឿង ព្រមទាំងចម្លើយសារភាពរបស់កូនក្តីខ្ញុំ ឃើញថាកូនក្តីរបស់ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន តែដោយសារស្ថានភាពគ្រួសាររបស់ខ្លួនមានភាពក្រីក្រ និងចំណេះដឹងរបស់កូនក្តីខ្ញុំនៅមានកម្រិតដែលធ្វើឱ្យមានការកើតឡើងនៃអង្គហេតុនេះ។ ម្យ៉ាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមានចំពោះមុខតុលាការនៅពេលនេះក៏ស្នើសុំសំណងចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ដើម្បីបញ្ចប់ការទាមទាររបស់ខ្លួនដែរ ចំណែកដើមបណ្តឹងរដ្ឋប្បវេណី ០២នាក់ ផ្សេងទៀត បានលះបង់សិទ្ធិទាមទារសំណងរដ្ឋប្បវេណីហើយ ដូចនេះក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំតុលាការមេត្តាផ្តល់ស្ពាន សម្រាលដល់រូបកូនក្តីខ្ញុំ។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ឆេងអ័ន** បានធ្វើសេចក្តីសន្និដ្ឋានថា៖ យោងតាមអង្គហេតុ អង្គច្បាប់ និងការសួរដេញដោលនាពេលសវនាការ អាចធ្វើសេចក្តីសន្និដ្ឋានបានថា៖ ឈ្មោះ [redacted] ឃាន់ ពុំបានចូលរួមក្នុងអំពើប្រព្រឹត្តបទល្មើស លួចមានស្ថានទម្ងន់ទោស (ឆក់កាបូបលុយ)



Scanned with CamScanner

កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ដូចការចោទប្រកាន់ទេ។ ម្យ៉ាងវិញទៀតជនជាប់ចោទឈ្មោះ [redacted] ឆេងអ័ន បានឆ្លើយនៅពេលសវនាការបញ្ជាក់ថា ខ្លួនទៅតែម្នាក់ឯង ហើយពុំមានការចូលរួមផ្តល់ជំនួយ ឬការឧបត្ថម្ភដល់ការប្រព្រឹត្តបទល្មើសដោយឈ្មោះ [redacted] ឃាន់ ឡើយ។ ជាមួយគ្នានេះ បន្ទាប់ពីបានលឺជនជាប់ចោទបបួល ហើយឈ្មោះ [redacted] ឃាន់ គ្រាន់តែឆ្លើយ អឺ ហើយក៏គេចចេញទៅណាបាត់ មិនបានធ្វើសកម្មភាពនោះទេ ហើយក៏ពុំមានការចូលរួមជាមួយជនជាប់ចោទឈ្មោះ [redacted] ឆេងអ័ន ដែរ។ ដូចនេះ ស្នើសុំអង្គសវនាការទាំងមូលមេត្តាសម្រេចអនុញ្ញាតឱ្យកូនក្តីខ្លួន រួចផុតពីបទចោទប្រកាន់ចាប់ពីពេលនេះតទៅដោយក្តីអនុគ្រោះ។

**-ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលនាសវនាការ**

**-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឆេងអ័ន**

**-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឃាន់**

**-ក្រោយពីបានស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌**

**-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមស្រ៊ុន**

**-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូអ៊ាន និងឈ្មោះ [redacted] ចន្ថា**

**-ក្រោយពីបានពិនិត្យភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង**

**-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ**

**-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

**-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ**

## សាលាដំបូងខេត្តកំពង់ធំ

## សំអាងហេតុ:

[redacted]

១- តុលាការបានទទួលបណ្តឹងតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: **២៩ ១៥** ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ ដែលសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] **ឆេងអ័ន** ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣, ចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងចំណុចមុខផ្ទះជាងគំនូរផ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពី១១ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] **ឃាន់** ភេទប្រុស កើតឆ្នាំ២០០៤ ជាតិខ្មែរ ពីបទ៖ "**សមគំនិតលួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**២៩**, មាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ, សំណុំរឿងព្រហ្មទណ្ឌលេខ: **២៥៦** ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ និងវត្ថុតាង ព្រមទាំងបញ្ជីរាយនាមជនទាក់ទិនក្នុងសំណុំរឿង។

២- ឆ្លងតាមការសួរដេញដោលក្នុងសវនាការ, តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទ, តាមការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងការពិនិត្យភស្តុតាងជាឯកសារនៅក្នុងសំណុំរឿង និងវត្ថុតាងពាក់ព័ន្ធអាចឱ្យតុលាការជឿជាក់បានថា: ចំណុចភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣, ចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងចំណុចមុខផ្ទះជាងគំនូរផ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពី១១ ខែមេសា ឆ្នាំ២០២៣ ពិតជាមានអង្គហេតុនៃបទល្មើស "**លួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **ឆេងអ័ន** ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ និងកាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ស្ថិតនៅចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ពិតជាមានអង្គហេតុនៃបទល្មើស "**សមគំនិតលួចមានស្ថានទម្ងន់ទោស(ឆក់**



Scanned with CamScanner

**ឆក់កាបូបលុយ)**" ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **យ៉ាន់** ភេទប្រុស កើតឆ្នាំ២០០៤ ជាតិខ្មែរ ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន។

៣- តាមបញ្ញត្តិ**មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ** "អំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន" គឺ**ជាអំពើ ល្មួច**។

៤- តាមបញ្ញត្តិ**មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ** "អំពើលួចប្រព្រឹត្តឡើងមុនពេល, ក្នុងពេល ឬក្រោយពេលប្រើហិង្សា និងប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ" គឺជាអំពើលួចមានស្ថានទម្ងន់ទោស។

៥- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឆេងអ៊ន ដែលបានធ្វើសកម្មភាពឆក់កាបូបប្រាក់ជនរងគ្រោះដែលកំពុងបើកបរតាមផ្លូវ ក្នុងគោលបំណងយកទ្រព្យសម្បត្តិអ្នកដទៃ (កាបូបប្រាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី) នោះមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ត្រូវកំណត់ថា ជាបទល្មើស **លួចមានស្ថានទម្ងន់ទោស**។

៦- តាមបញ្ញត្តិ**មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ** ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្របសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិម នោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន [...] កាលណាបើបទល្មើសនេះ ជាអំពើសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នា និងចារីដែរ គឺ**ជាអំពើសមគំនិត**។

៧- ឈ្មោះ [redacted] **យ៉ាន់** បានឆ្លើយបញ្ជាក់នៅចំពោះមុខចៅក្រមស៊ើបសួរថាខ្លួនពុំបានចូលរួមសកម្មភាពជាមួយឈ្មោះ [redacted] ឆេងអ៊ន នោះទេដែលចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានឆ្លើយបំភ្លឺកន្លងមក ឃើញថាឈ្មោះ [redacted] យ៉ាន់ ពិតជាពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ ម្យ៉ាងទៀតក៏ពុំមានសាក្សីណាបានឃើញឈ្មោះនេះចូលរួមសកម្មភាពឆក់កាបូបជាមួយឈ្មោះ [redacted] ឆេងអ៊ន ឡើយ។ ការឆ្លើយរបស់ឈ្មោះ [redacted] ឆេងអ៊ន ថាមានឈ្មោះ [redacted] យ៉ាន់ ចូលរួមប្រព្រឹត្តនោះ គ្រាន់តែជាចេតនាដោះសារនិងទម្លាក់កំហុសទៅលើអ្នកដទៃ ដើម្បីទទួលស្ថានសម្រាលមកខ្លួនឯង ប៉ុណ្ណោះ។ ដូចនេះគប្បីតុលាការពិនិត្យ និងសម្រេច។

៨- មានភស្តុតាងដាក់បន្ទុក និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទដែលអាចឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ឆេងអ៊ន** ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣, ចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងចំណុចមុខផ្ទះជាងគំនូរឆ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពី១១ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

៩- គ្មានភស្តុតាងដាក់បន្ទុក លើជនជាប់ចោទឈ្មោះ [redacted] **យ៉ាន់** ភេទប្រុស កើតឆ្នាំ២០០៤ ជាតិខ្មែរ ពីបទ៖ "**សមគំនិតលួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**២៩**, មាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ឡើយ។

១០- ជនជាប់ចោទឈ្មោះ [redacted] ឆេងអ៊ន ជានីតិជន និងមិនមានភស្តុតាង ឬសញ្ញាណណាដែលបញ្ជាក់ថាជននេះមានវិបល្លាសស្មារតីទេ ហេតុដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។ អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងរបៀបរៀបរយក្នុងសង្គម ជាពិសេសបំពានលើបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១១- តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ឆេងអ៊ន** ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣, ចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងចំណុចមុខផ្ទះជាងគំនូរឆ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពី១១ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ



Scanned with CamScanner

និងប្ដឹងសុំឱ្យតុលាការសម្រេចឱ្យឈ្មោះ [redacted] **ឃាន់** ភេទប្រុស កើតឆ្នាំ២០០៤ ជាតិខ្មែរ រួចខ្លួនពីបទចោទ ពីបទ៖ "**សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៩, មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**១២**- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឆេងអ័ន: ស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនដោយសារខ្លួនដឹងអំពីកំហុសហើយ។ ចំណែកឯមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឃាន់ ស្នើសុំតុលាការសម្រេចឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទ ដោយសារកូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គប្បីតុលាការសម្រេចពិចារណា។

**១៣**- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គីមស្រ៊ុន បានបញ្ជាក់នាចំពោះមុខសវនាការទាំងមូលថា ខ្លួនសូមដកពាក្យបណ្ដឹង ឈប់ប្ដឹងទាមទារសំណងលើជនជាប់ចោទឈ្មោះ [redacted] ឆេងអ័ន ភេទប្រុស គប្បីតុលាការមិនសម្រេចអំពីសំណង។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរ៉ាន និងឈ្មោះ [redacted] ចន្ថា បានដកពាក្យបណ្ដឹងឈប់ប្ដឹងទាមទារសំណងតាមរយៈកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយ ចុះថ្ងៃទី រួចហើយ ដូចនេះ គប្បីតុលាការមិនសម្រេចអំពីសំណងឡើយ។

**១៤**- យោងកំណត់ហេតុទទួលស្គាល់វត្ថុចាប់យកលេខ ៩១ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ ដែលមានវត្ថុចាប់យករួមមាន៖

១. ទូរស័ព្ទម៉ាក អូប៉ូ (OPPO) ពណ៌ខ្មៅ ចំនួន ០១គ្រឿង គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមឈ្មោះ [redacted] ឆេងអ័ន វិញ។

**១៥**- សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ឆេងអ័ន៖ សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង ឱ្យឆាប់មានសេរីភាព វិលទៅរកសង្គមជាតិវិញ ឆាប់បានទៅរៀនវិញ ដោយខ្លួនបានដឹងអំពីកំហុសហើយ និងសន្យាឈប់ប្រព្រឹត្តទង្វើនេះទៀតហើយ គប្បីតុលាការសម្រេចពិចារណា។

**១៦**- សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ឃាន់៖ សូមតុលាការមេត្តាសម្រេចឱ្យខ្លួនរួចផុតពីបទចោទដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គប្បីតុលាការសម្រេចពិចារណា។

## ហេតុដូច្នេះ

## សាលាដំបូងខេត្តកំពង់ធំ វិនិច្ឆ័យសេចក្ដី

**<u>១-ផ្ដន្ទាទោស៖</u>**

**១.១**.ឈ្មោះ [redacted] **ឆេងអ័ន** ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ (សាវតារជាតិខាងលើ) "ក្នុងឃុំ" ដាក់ពន្ធនាគារ កំណត់រយៈពេល **១៤ (ដប់បួន) ខែ** ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣, ចំណុចភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងចំណុចមុខផ្ទះជាងគំនូរឆ្លាមសមុទ្រ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពី១១ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**១.២**. ឱ្យឈ្មោះ [redacted] **ឃាន់** ភេទប្រុស កើតឆ្នាំ២០០៤ ជាតិខ្មែរ (សាវតារជាតិខាងលើ) រួចខ្លួនពីបទចោទប្រកាន់ ពីបទ៖ "**សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស(ឆក់កាបូបលុយ)**" ប្រព្រឹត្តនៅភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៩ មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

កំពង់ធំ ថ្ងៃទី២៥ ខែ...... ឆ្នាំ២០២៤



[redacted]

<u>២-ប្រគល់វត្ថុចាប់យករួមមាន៖</u>

១. ទូរស័ព្ទម៉ាក អូប៉ូ (OPPO) ពណ៌ខ្មៅ ចំនួន ០១គ្រឿង ឱ្យម្ចាស់ដើមឈ្មោះ ឆន ឆេងអ៊ន វិញ។

សាលក្រមនេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី**២៧** **ខែកញ្ញា** ឆ្នាំ**២០២៣** និងប្រកាសជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ នៅថ្ងៃទី**២៦** **ខែតុលា** ឆ្នាំ**២០២៣** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ឆេងអ៊ន** និងឈ្មោះ [redacted]**យ៉ាន់**។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

**បានឃើញ**

កំពង់ធំ ,ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពស. ២៥៦៧

កំពង់ធំ ,ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពង់ធំ, ថ្ងៃទី..២៥..ខែមករា.ឆ្នាំ២០២៤

[illegible]........................................

ក្រឡាបញ្ជី

[redacted]